IFC International Finance Corporation World Bank Group

ILO អង្គការពលកម្មអន្តរជាតិ

រោងចក្រកាន់តែប្រសើរ នៅកម្ពុជា

# តំណាងអ្នកបញ្ជាទិញអន្តរជាតិធំៗនៅតែមានភាពវិជ្ជមានពីការទិញសំលៀកបំពាក់ពីកម្ពុជា

តំណាងអ្នកបញ្ជាទិញសំលៀកបំពាក់ធំៗចំនួន ២៨ ដែលបានមកចូលរួមកិច្ចប្រជុំនៅប្រទេសកម្ពុជាចំនួនពីរថ្ងៃកាលពីសប្តាហ៍មុនក្នុងវេទិកាអ្នកបញ្ជាទិញអន្តរជាតិ ដែលរៀបចំដោយអង្គការពលកម្មអន្តជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និយាយថាពួកគេនឹងស្នើរឱ្យក្រុមហ៊ុនរបស់ពួកគេបន្តទិញសំលៀកបំពាក់ពីប្រទេសកម្ពុជា។

អ្នកចូលរួមក្នុងវេទិកានៅតែមានសុទិដ្ឋិនិយមពីវិស័យឧស្សាហកម្មកាត់ដេរកម្ពុជា នេះបើយោងតាមប្រសាសន៍របស់លោក ទ័រម៉ូ ប៉ូទីអៃណិន (Tuomo Poutiainen) ប្រធានទីប្រឹក្សាបច្ចេកទេសនៃ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* របស់អង្គការពលកម្មអន្តជាតិ។ «អ្នកចូលរួមទាំងអស់បានប្រាប់ថា អាស្រ័យលើតម្រូវការរបស់អតិថិជនការបន្តពិនិត្យឃ្លាំមើលពី *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* និងការបន្តទទួលបានលទ្ធផលល្អ ក្រុមហ៊ុនរបស់ពួកគេមានភាពវិជ្ជមានពីការបញ្ជាទិញសំលៀកបំពាក់ពីប្រទេសកម្ពុជា»។

មានម៉ាកផលិតផលសំលៀកបំពាក់ចំនួន ៣២ ដែលជាសមាជិកនៃវេទិកានេះ ទិញផលិតផលចំនួន ៦០ ភាគរយនៃសំលៀកបំពាក់នាំចេញរបស់កម្ពុជាដែលជាឧស្សាហកម្មមួយមានតំលៃប្រមាណ ២.៦ កោដិដុល្លាអាមេរិច ហើយជាវិស័យដែលមានសារៈសំខាន់បំផុតចំពោះកម្មករនិយោជិកចំនួនជាង៣៥ម៉ឺននាក់ និងក្រុមគ្រួសារដែលមានសមាជិកច្រើនរបស់ពួកគេដែលពឹងផ្អែកពីចំណូលបានពីឧស្សាហកម្មនេះ (ចំនួនសរុបយ៉ាងហោចណាស់ក៏ ១.៧លាននាក់)។

វេទិកាដែលធ្វើឡើង២ដងក្នុងមួយឆ្នាំនៅប្រទេសកម្ពុជានិងទីក្រុងហុងកុង ត្រូវបានរៀបចំឡើងដោយអង្គការពលកម្មអន្តជាតិ និងសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិដើម្បីពិភាក្សាពីការងារបច្ចុប្បន្ន និងអនាគតនៃ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ហើយក៏ពិភាក្សាផងដែរនូវវិធីគាំទ្រដើម្បីបង្កើនការប្រកួតប្រជែងសម្រាប់ឧស្សាហកម្មសំលៀកបំពាក់កម្ពុជា ដើម្បីធ្វើឱ្យឧស្សាហកម្មនេះបន្តការលូតលាស់។ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ផ្តល់ការត្រួតពិនិត្យលក្ខខណ្ឌការងារ និងការបណ្តុះបណ្តាលសម្រាប់ឧស្សាហកម្មនាំចេញសំលៀកបំពាក់។ វេទិកានេះ ប្រព្រឹត្តិឡើងក្រោមកិច្ចសហការ និងផ្តល់មូលនិធិដោយកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គដែលជាការផ្តួចផ្តើមអភិវឌ្ឍន៍វិស័យឯកជនក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា។កម្មវិធីនេះគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិដែលមានប្រទេសម្ចាស់ជំនួយដូចជាអូស្ត្រាលី កាណាដា ហ្វាំងឡង់

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ អៀឡង់ ជប៉ុន ណូវែលហ្ស៊ីឡង់ ហូឡង់ ន័រវេ ស៊ុយអែត និងស្វីស ។

តំណាងអ្នកបញ្ជាទិញទាំងអស់បានជួបពិភាក្សាគ្នាអស់រយៈពេលកន្លះថ្ងៃដំបូង បន្ទាប់មកជួបដាច់ដោយឡែកជាមួយអ្នកផលិត និងបន្ទាប់មកជាមួយសហជីព។ នៅថ្ងៃទីពីរ អ្នកពាក់ព័ន្ធនឹងឧស្សាហកម្មសំលៀកបំពាក់ទាំងបួនក្នុងនោះមានសមាជិកវេទិកា អ្នកផលិត សហជីព និងរដ្ឋាភិបាលជួបគ្នាដើម្បីបង្កើតចក្ខុវិស័យរួមមួយសម្រាប់អនាគតឧស្សាហកម្មនេះ ។

លោក ទ័រម៉ូ ប៉ូទីអៃណិន (Tuomo Poutiainen) បាននិយាយថាកិច្ចប្រជុំនេះគឺជាជោគជ័យយ៉ាងអស្ចារ្យ ។ «*វាបានបញ្ជាក់នូវភាពទាក់ទង និងសារៈសំខាន់របស់ គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* និងជំនឿរបស់អ្នកពាក់ព័ន្ធទាំងឡាយ និងការគាំទ្រលើទិសដៅថ្មីរបស់គំរោង ។ វាក៏មានការយល់ស្របគ្នាថាអ្នកចូលរួមចំណែកក្នុងវិស័យនេះទាំងអស់ ត្រូវការធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ហើយគំរោងនេះត្រូវធ្វើការឱ្យលើសពីការត្រួតពិនិត្យឃ្លាំមើល ហើយពង្រីកបន្ថែមការបណ្តុះបណ្តាល។ គំនិតនេះត្រូវបានយល់ស្របដោយអ្នកពាក់ព័ន្ធទាំងឡាយ។ »

លោកស្រី ណូរីនម៉ូហ្សាហ្វា (Ms.Naurin Muzaffar) នាយិកាជាន់ខ្ពស់ផ្នែកភាពជាដៃគូរអន្តរជាតិរបស់ក្រុមហ៊ុន GAP Inc បានសរសើរពីការវិវត្តន៍នៃវេទិកា និង*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ។ «ពីមួយឆ្នាំទៅមួយឆ្នាំ កិច្ចប្រជុំកាន់តែប្រសើរឡើង ។ ការចូលរួមចំណែករបស់សហជីពក្នុងវេទិការនេះពិតជាល្អបំផុត ការពិភាក្សាត្រូវបានរៀបចំយ៉ាងល្អ និងផុសផុល។*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានវិវត្តន៍យ៉ាងច្រើនតាំងពីមានតែការត្រួតពិនិត្យឃ្លាំមើល រហូតមានសេវាកម្មប្រឹក្សាយោបល់ ការអភិវឌ្ឍន៍សមត្ថភាព និងយន្តការជាច្រើនទៀតដែលចាំបាច់សម្រាប់បញ្ហាទាំងនេះ »។

លោក អៀរិកកាលប៊ិក (Mr.Erik Carlborg)នាយកផ្នែកនិតិវិធីរបស់ក្រុមហ៊ុនH&Mបាននិយាយថាការអនុលោមតាមស្តង់ដារច្បាប់ គឺជាផ្នែកមួយយ៉ាងសំខាន់នៃយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ក្រុមហ៊ុនH&M ហើយថាពួកគេប្រាកដណាស់ថា*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺជាអ្នកចូលរួមចំណែកយ៉ាងវិជ្ជមានដើម្បីអោយមានកម្រិតនៃការអនុលោមតាមច្បាប់ល្អក្នុងវិស័យឧស្សាហកម្មសំលៀកបំពាក់កម្ពុជា ។

តំណាងពីសមាគមរោងចក្រកាត់ដេរកម្ពុជា លោក កាំង ម៉ូនីកា (Mr.Kaing Monika) បានលើកឡើងពីអ្វីដែលឧស្សាហកម្មកំពុងតែធ្វើដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងជាលក្ខណៈជាតិ។ លោកបាននិយាយថា «ដោយសារតែវាជាឧស្សាហកម្មអន្តជាតិ វាតែងតែមានការប្រកួតប្រជែងជាលក្ខណៈអន្តជាតិ ដូច្នេះការកសាងភាពប្រកួតប្រជែងជាលក្ខណៈជាតិ គឺជាបញ្ហាប្រឈមយ៉ាងសំខាន់សម្រាប់យើង »។ គាត់បានបន្ថែមទៀតថាការ

កាត់បន្ថយចំណាយក្នុងការធ្វើជំនួញ មានសារៈសំខាន់សម្រាប់ពង្រឹងភាពប្រកួតប្រជែង ហើយរដ្ឋាភិបាលកំពុងធ្វើការងារយ៉ាងច្រើនលើបញ្ហានេះ ប៉ុន្តែដោយសារស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន យើងត្រូវការការគាំទ្របន្ថែមទៀត។ ការធ្វើឱ្យចុះសម្រុងគ្នាលើផ្នែកទំនាក់ទំនងវិជ្ជាជីវៈ គឺមានសារៈសំខាន់សម្រាប់ធ្វើឱ្យផលិតកម្មមានស្ថេរភាព និងមានទំនុកចិត្តពីអ្នកទិញទាំងអស់។ ជាចុងក្រោយ វាមានភាពចាំបាច់ដើម្បីលើកឡើងពីការយល់ដឹងរបស់កម្មករនិយោជិតស្តីពីការងាររបស់ពួកគេ។ ពួកគេ គួរតែមានការជំរុញទឹកចិត្តមិនត្រឹមតែធ្វើឱ្យប្រសើរឡើងនូវជំនាញឥឡូវរបស់ពួកគេនោះទេ ប៉ុន្តែគួរជំរុញឱ្យមានការបណ្តុះបណ្តាលពីជំនាញថ្មីៗផងដែរ »។

តំណាងសហជីពដែលចូលរួមក្នុងវេទិកាបានស្នើរសុំឱ្យអ្នកបញ្ជាទិញគាំទ្រលើបញ្ហាសំខាន់ៗដូចជា បង្កើនសិទ្ធិក្នុងការបង្កើតអនុសញ្ញារួម និងសេរីភាពក្នុងការបង្កើតអង្គការវិជ្ជាជីវៈ។ ថ្លែងជំនួសមុខអោយសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងសហជីពជាង១០ទៀតដែលចូលរួមក្នុងវេទិកា លោកអាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បាននិយាយថាសហជីពមានការព្រួយបារម្ភពីកម្មករនិយោជិកដែលត្រូវប្រឈមជាមួយនឹងអតិផរណាខ្ពស់ ហើយស្នើរសុំឱ្យអ្នកបញ្ជាទិញទាំងអស់ដាក់បញ្ជាទិញរយៈពេលវែងជាមួយរោងចក្រ ដើម្បីឱ្យកម្មករនិយោជិកកាន់តែមានស្ថេរភាពលើការងារ។

ថ្លែងនៅក្នុងពិធីជប់លៀងសម្រាប់កិច្ចប្រជុំ លោកស្រី កាឡា គីហ្សូន (Ms.Karla Quizon) នាយិកានៃកម្មវិធីនិរន្តភាពបរិស្ថាន និងសង្គមកិច្ចក្នុងតំបន់ទន្លេមេគង្គនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បាននិយាយថាកិច្ចប្រជុំនេះទទួលបានលទ្ធផលជាច្រើន។ «ឆ្នាំនេះមានតំណាងអ្នកបញ្ជាទិញយកពីម៉ាកផ្សេងៗទៀតកាន់តែច្រើន បានចូលរួមកិច្ចប្រជុំ ហើយចុងក្រោយពួកគេសន្យាក្នុងការចូលរួមចំណែកធ្វើឱ្យបានផុសផុលបន្ថែមទៀតដើម្បីឱ្យឧស្សាហកម្មសំលៀកបំពាក់កម្ពុជាបន្តលូតលាស់ក្នុងរយៈពេលយូរអង្វែង » ។

ថ្លែងទៅកាន់បណ្តាអ្នកបញ្ជាទិញ និងអ្នកពាក់ព័ន្ធទាំងអស់ ឯកឧត្តម ចម ប្រសិទ្ធិ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសង្កត់ធ្ងន់ពីសារៈសំខាន់របស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ។ «ផែនការត្រួតពិនិត្យរបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តជាតិ គឺជាប្រព័ន្ធល្បីដាប់ថ្នាក់ពិភពលោកដែលជួយឱ្យអ្នកបញ្ជាទិញទុកចិត្តកម្ពុជា ហើយចាត់ទុកប្រទេសនេះជាប្រភពសម្រាប់នាំចេញសំលៀកបំពាក់ ។ ខ្ញុំបានទទួលសំណើរពីប្រទេសជាច្រើនក្នុងការមកកាន់កម្ពុជា និងរៀនពីបទពិសោធន៍របស់យើងនៅទីនេះ ។ រដ្ឋាភិបាលនឹងបន្តផ្តល់ការគាំទ្រយ៉ាងពេញទំហឹងលើគំរោងនេះហើយបង្កើតយន្តការជាច្រើនទៀតសម្រាប់កិច្ចសន្ទនារវាងសហជីព និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា »។

ទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែង លោកដេវីត អេដ្រៀនរ៉ូស (David AdrianRoss) នាយកចាត់ការទូទៅនៃរោងចក្រ New Island Clothing (Cambodia) Ltd. បាននិយាយថាគាត់ពិតជាមានសុទិដ្ឋិនិយមពីក្តីសង្ឃឹមធ្វើឱ្យប្រសើរឡើងនូវជំនាញ និងផលិតភាពរបស់កម្មករនិយោជិកក្នុងឧស្សាហកម្មសំលៀកបំពាក់កម្ពុជា។

«ផលិតភាព ស្តង់ដារគុណភាព និងការប្តេជ្ញាចិត្តរបស់កម្មករនិយោជិកខ្ញុំ គឺល្អគ្មានពីរ ។ ពួកយើងពិតជាមានមោទនភាពចំពោះការពិតដែលថារោងចក្រយើងស្ទើរតែ ១០០ភាគរយគ្រប់គ្រង់ដោយជនជាតិកម្ពុជា ។នៅទីបំផុត គោលបំណងសំខាន់ គឺមិនមែនជួលជនបរទេសឱ្យធ្វើការទេ ប៉ុន្តែជាជនជាតិកម្ពុជា »។

ក្នុងកំឡុងពេលពីរថ្ងៃនៃវេទិកា សមាជិកអ្នកបញ្ចាទិញទាំងឡាយ បានប្រាប់បុគ្គលិកអង្គការពលកម្មអន្តជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិថា ពួកគេពិតជារីករាយជាមួយលទ្ធផលដែលសំរេចបានក្នុងកិច្ចប្រជុំដែលបានផ្តល់ឱ្យពួកគេនូវឱកាសដ៏ពិសេសដើម្បីស្តាប់ដោយផ្ទាល់នូវកង្វល់របស់រោងចក្រ សហជីព និងរដ្ឋាភិបាល ។ លោក ទំរម៉ូ ប៉ូទីអៃណិន (Tuomo Poutiainen) បានមានប្រសាសន៍ថា «សមាជិកវេទិកាទាំងមូល និយាយថាក្នុងប៉ុន្មានខែខាងមុខពួកគេមានគំរោងបន្តសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីស្វែងរកដំណោះស្រាយទៅលើបញ្ហាដែលបានលើកឡើងក្នុងវេទិកា »។ គាត់បានបន្តថា «សម្រាប់អនាគតរបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* វាច្បាស់ណាស់ថាកិច្ចប្រជុំនេះបង្ហាញថាវិស័យឧស្សាហកម្មសំលៀកបំពាក់កម្ពុជាបន្តមានភាពទាក់ទាញ និងពិសេសសម្រាប់អ្នកបញ្ចាទិញអន្តរជាតិ ហើយការបញ្ចាទិញប្រកបដោយក្រមសីលធម៌នៅតែជាកត្តាសំខាន់សម្រាប់ជោគជ័យនៃឧស្សាហកម្មនេះ »។

.......................................................................................................

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**
លោក នី យូ
អង្គការពលកម្មអន្តជាតិ_ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*
លេខ ៩ ផ្លូវ៣២២ បឹងកេងកង១ ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១២ ៨៤៧
ទូរស័ព្ទដៃលេខ (៨៥៥) ១២ ៣៧៣ ៨៧៧
អ៊ីម៉ែល you@ilo.org

លោកស្រី អាន ប៊ីហ្សប
សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
អគារ ៧០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១០ ៩២២
ទូរស័ព្ទដៃលេខ (៨៥៥) ១២ ៩៣១ ២៤៤
អ៊ីម៉ែល abishop1@ifc.org

## សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសមាជិករបស់ក្រុមធនាគារពិភពលោក បង្កើតកាលានុវត្តភាពដើម្បីអោយប្រជាជនចាកផុតពីភាពក្រីក្រ និងបង្កើនជីវភាពរបស់ពួកគេ ។ ពួកយើងជួយជំរុញសេដ្ឋកិច្ច នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានាអោយលូតលាស់ប្រកបដោយនិរន្តរភាព តាមរយៈការគាំទ្រដល់ការអភិវឌ្ឍន៍វិស័យឯកជន កៀរគ និងបែងចែកមូលធនឯកជន ផ្តល់សេវាប្រឹក្សាយោបល់ និង សេវាសម្រាលហានិភ័យដល់អាជីវកម្ម និងរដ្ឋាភិបាល ។ ទុនវិនិយោគសរុបបច្ចុប្បន្ន របស់យើងមានចំនួន ១៦,២ ពាន់លានដុល្លាអាមេរិកនៅក្នុងឆ្នាំ ២០០៨ ដែលកើនឡើងលើសឆ្នាំមុន ៣៤% ។ សំរាប់ព័តិមានបន្ថែម សូមមើល គេហទំព័រ www.ifc.org.

## រោងចក្រកាន់តែប្រសើរនៅកម្ពុជា

***រោងចក្រកាន់តែប្រសើរនៅកម្ពុជា*** (BFC)គឺជាកម្មវិធីពិសេសមួយរបស់អង្គការពលកម្មអន្តរជាតិ ។កម្មវិធីនេះផ្តល់ប្រយោជន៍ដល់កម្មករ និយោជិតនិយោជកនិងអង្គភាពរបស់គេផង ។ កម្មវិធីនេះក៏ផ្តល់ផលប្រយោជន៍ផងដែរដល់អ្នកប្រើប្រាស់ផលិតផលនៅតាមបណ្តាប្រទេសលោកខាងលិច ព្រមទាំងជួយកាត់បន្ថយភាពក្រីក្ររបស់ ប្រទេសក្រីក្រមួយ ក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក ។

កម្មវិធីនេះផ្តល់នូវគុណប្រយោជន៍បែបនេះ តាមរយៈការតាមឃ្លាំមើល និងការរាយការណ៍អំពីល័ក្ខខ័ណ្ឌការងារនៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជាដោយអនុលោមទៅតាមបទដ្ឋានជាតិ និងអន្តរជាតិតាមរយៈការជួយរោងចក្រសហគ្រាសក្នុងការលើកកំពស់ផលិតភាព និងតាមរយៈការធ្វើការជាមួយរដ្ឋាភិបាល និងអ្នកទិញអន្តរជាតិដើម្បីធានាអោយមានវដ្តនៃការរីកចំរើនប្រកបដោយភាពហ្មត់ចត់ និងតម្លាភាព ។

កម្មវិធីនេះ កើតចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយរវាងសហរដ្ឋអាមេរិកនិងកម្ពុជា ។ ក្រោមកិច្ចព្រមព្រៀងនេះសហរដ្ឋអាមេរិកបានសន្យាអោយកម្ពុជានាំចូលនូវផលិតផលទៅកាន់ទីផ្សារសហរដ្ឋអាមេរិកជាការប្តូរនឹងការសុំអោយមានលក្ខខណ្ឌការងារល្អប្រសើរក្នុងវិស័យកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ។ គំរោងកម្មវិធីរបស់អង្គការពលកម្មអន្តរជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ ដើម្បីជួយអោយវិស័យនេះសំរេច និងរក្សាអោយបាននូវការរីកចំរើនបែបនេះ ។

***រោងចក្រកាន់តែប្រសើរនៅកម្ពុជ ា*** កាលពីមុនមានឈ្មោះថា គំរោងកែលំអលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេររបស់អង្គការពលកម្មអន្តរជាតិ ។ ឈ្មោះថ្មីនេះឆ្លុះបញ្ចាំងនូវគោលបំណងបច្ចុប្បន្ន របស់គំរោងអង្គការពលកម្ម អន្តរជាតិ បានប្រសើរជាងមុន ។

## អង្គការពលកម្មអន្តរជាតិ

អង្គការពលកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩១៩ដោយសន្ធិសញ្ញាវៀកសៃ (Treaty of Versailles) ហើយបានក្លាយជាទីភ្នាក់ងារជំនាញដំបូងបង្អស់របស់ប្រពន្ធ័សហប្រជាជាតិក្នុងឆ្នាំ១៩៤៦ ។ ការងារក្នុងការដោះស្រាយ និងត្រួតពិនិត្យស្តង់ដារការងារអន្តរជាតិផ្តល់គំរោងការសម្រាប់ច្បាប់ការងារជាតិនិងការអនុវត្តស្មើរតែគ្រប់បណ្តាប្រទេសទាំងអស់ ។ ថវិកាសរុបរបស់អង្គការពលកម្មអន្តរជាតិសម្រាប់ឆ្នាំ ២០០៦-២០០៧ គឺជាង ៩០០លានដុល្លាអាមេរិច ដោយរួមបញ្ចូលទាំងថវិកាជាប្រចាំចំនួន ៥៩៤លានដុល្លាអាមេរិច និង ៣០៦លានដុល្លាអាមេរិចទៀត ក្នុងមូលនិធិបន្ថែមដែលទាក់ទងនឹងគំរោងសហប្រតិបត្តិការបច្ចេកទេសពិសេស ។ សម្រាប់ពិត័មានបន្ថែម សូមមើល គេហទំព័រ www.ilo.org